# គោលការណ៍ណែនាំក្នុងការប្រើប្រាស់បញ្ជីកត់ត្រា ស្តីពីការព្យាបាលជំងឺឱកាសនិយម (មុនពេល ART)

## [Pre-ART (OI) Register]

បញ្ជីស្តីពីការព្យាបាលជំងឺឱកាសនិយម (មុនពេល ART) គឺជាបញ្ជីដែលត្រូវបានកត់ត្រាអ្នកជំងឺដែលទទួលការពិនិត្យ និងព្យាបាលជំងឺឱកាសនិយមនៅតាមមន្ទីរពេទ្យបង្អែក/គ្លីនិកដែលមានទទួលពិនិត្យនិងព្យាបាលអ្នកជំងឺអេដស៍។

ខ្លឹមសារ និងរបៀបប្រើប្រាស់បញ្ជីនេះមានដូចជា ៖

| ១ | ២ | | | | | ៣ | ៤ | | | | ៥ | ៦ | ៧ | | | | ៨ | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ថ្ងៃ ខែ ឆ្នាំចុះបញ្ជី ពេលព្យាបាល HIV | លេខកូដអ្នកជំងឺ | | | | | ឈ្មោះ | អាយុ និងភេទ | | | | អាស័យដ្ឋាន (ឃុំ ស្រុក ខេត្ត) | លេខស្រាបចាប់ផ្តើម ART | អ្នកជំងឺចាកចេញ | | | | ខែទី ១ | | | | | | | |
| | | | | | | | ប្រុស Man > 14 | ស្រី Woman > 14 | ក្មេងប្រុស Boy 0-14 | ក្មេងស្រី Girl 0-14 | | | បាត់មុខ | ស្លាប់ | ចាប់ផ្តើម ART | ថ្ងៃ ខែ ឆ្នាំ | ថ្ងៃ ខែ ឆ្នាំ ពិនិត្យ | មានផ្ទៃពោះ | ពិនិត្យស្រាវជ្រាវរកការសង្ស័យជំងឺរបេង TB Screen (+/-) | ចាប់ផ្តើមព្យាបាលបង្ការដោយ INH (IPT) | ចាប់ផ្តើមព្យាបាលបង្ការដោយ Cotrimoxazole (CPT) | រោគវិនិច្ឆ័យថាមានកើតជំងឺរបេង (BK+/-; EP) | ចាប់ផ្តើមព្យាបាលជំងឺរបេង (TB Tx) | ការបង្ការជាវិជ្ជមាន Positive Prevention |
| / / | | | | | | | | | | | | | | | | / / | / / | | | | | | | ☐ STI Prevention<br>☐ ART Adherence<br>☐ Birth spacing<br>☐ TB IC<br>☐ Partner Status<br>☐ Condom used |

### ១- ថ្ងៃ ខែ ឆ្នាំចុះបញ្ជី

គឺជាកាលបរិច្ឆេទដំបូងដែលអ្នកជំងឺបានមកទទួលការពិនិត្យនិងព្យាបាលជំងឺឱកាសនិយមនៅក្នុងគ្លីនិក/មន្ទីរ ពេទ្យបង្អែក ក្រោយពីបានទទួលលទ្ធផលថាមានផ្ទុកមេរោគអេដស៍ដែលមានការបញ្ជាក់ច្បាស់លាស់ពីសេវាធ្វើតេស្តឈាមរកមេរោគអេដស៍ ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់។

ឧ. មានអ្នកជំងឺម្នាក់មកទទួលការពិនិត្យនិងព្យាបាលជំងឺឱកាសនិយមនៅថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ២០១០ ដូច្នេះកាលបរិច្ឆេទ នេះគឺជាថ្ងៃខែឆ្នាំដែលគាត់ត្រូវចុះឈ្មោះក្នុងបញ្ជី

### ២- លេខកូដអ្នកជំងឺ

គឺជាលេខកូដរបស់អ្នកជំងឺម្នាក់ៗដែលត្រូវបានផ្តល់អោយនៅពេលដែលគាត់មកទទួលយកសេវាព្យាបាលជំងឺឱកាសនិយម ដែលមាន ៥ ខ្ទង់ ដោយចាប់ផ្តើមជាលេខរៀងដំបូង និងបន្តបន្ទាប់ ។

ឧ. អ្នកជំងឺក្នុងឧទាហរណ៍ខាងលើ (១)ត្រូវផ្តល់លេខកូដគ្លីនិកអោយគាត់គឺ **0000១** ។

### ៣- ឈ្មោះ

គឺជាឈ្មោះរបស់អ្នកជំងឺដែលបានមកទទួលយកសេវាព្យាបាលជំងឺឱកាសនិយម។

ឧ. អ្នកជំងឺក្នុងឧទាហរណ៍ (១) និង (២) ឈ្មោះ XXXXXXXXXXXXX

### ៤- អាយុ និងភេទ

គឺជាអាយុនិងភេទរបស់អ្នកជំងឺម្នាក់ៗ ដែលមានការបែងចែកអាយុជា ៤ប្រភេទផ្សេងៗគ្នា ដោយគិតយកអាយុជាក់ស្តែង នៅថ្ងៃដែលគាត់មកពិនិត្យលើកដំបូង ៖

- ប្រុសអាយុលើស ១៤ឆ្នាំ
- ស្រីអាយុលើស ១៤ឆ្នាំ
- ក្មេងប្រុសអាយុ ពី 0 ដល់ ១៤ឆ្នាំ
- ក្មេងស្រីអាយុ ពី 0 ដល់ ១៤ឆ្នាំ

**៥- អាស័យដ្ឋាន**

គឺជាកន្លែងរស់នៅពិតប្រាកដរបស់អ្នកជំងឺម្នាក់ៗដោយសង្ខេបអំពីអាស័យដ្ឋានដែលអ្នកជំងឺកំពុងស្នាក់នៅ និងលេខទូរស័ព្ទ (ប្រសិនបើមាន) ដើម្បីងាយស្រួលក្នុងការទំនាក់ទំនងនៅពេលដែលមានការចាំបាច់ណាមួយត្រូវរកពួកគាត់ដូចជាការមកយឺតជាងការណាត់ជួបជាដើម។

**៦- សមស្របចាប់ផ្តើម ART**

Eligible ART: គឺជាអ្នកជំងឺដែលបានចាត់ទុកក្នុងដំណាក់កាល ទី៤ របស់ WHO , មានរោគសញ្ញានិងចាប់ផ្តើមព្យាបាលជំងឺរបេង ឬមាន CD4 ទាបជាង ៣៥០ ,មម³ ។ (ល័ក្ខណ្ឌទាំងនេះអាចនឹងមានការផ្លាស់ប្តូរនៅពេលដែលមានការផ្លាស់ប្តូរនៅក្នុងគោលការណ៍ណែនាំ)។

(ឧ. ប្រសិនបើសម ស្របចាប់ផ្តើម ART ប្រើសញ្ញា ✓ប្រសិនបើមិនសមស្របចាប់ផ្តើម ART ទេ ទុកនៅទំនេរ) ។

**៧- អ្នកជំងឺចាកចេញ**

**បាត់មុខ (Lost)**[1] ៖ រាប់នូវចំនួនអ្នកជំងឺដែល បញ្ជូនចេញ និង អ្នកជំងឺដែលបានកំណត់ថា បាត់មុខ ( អ្នកជំងឺទាំងឡាយដែលមិនបានមកកាន់គ្លីនិកចាប់ពីរយៈពេល ៦ខែ ឡើងទៅ) នៅក្នុងបញ្ជីចុះឈ្មោះអ្នកព្យាបាលជំងឺឱកាសនិយម (OI) គិតដល់ចុងត្រីមាសដែលរាយការណ៍ក្នុងរបាយការណ៍ ។ ពិនិត្យអោយច្បាស់ឡើងវិញថាអ្នកជំងឺទាំងនោះ មិនមែនជាអ្នកជំងឺដែលបានចាប់ផ្តើមទទួលការព្យាបាលដោយ ARV ទេ ។ (ឧ. ប្រសិនបើបាត់មុខ ប្រើសញ្ញា ✓ប្រសិនបើមិនបាត់មុខទេ ទុកនៅទំនេរ) ។

**ស្លាប់ (Died) :** គឺជាអ្នកជំងឺដែលបានទទួលការព្យាបាលជំងឺឱកាសនិយម (OI) ហើយយើងបានដឹងច្បាស់ថា ស្លាប់ក្នុងរយៈពេលកំពុងព្យាបាល ។ (ឧ. ប្រសិនបើអ្នកជំងឺស្លាប់ ប្រើសញ្ញា ✓ប្រសិនបើមិនស្លាប់ទេ ទុកនៅទំនេរ)

**ចាប់ផ្តើម ART (Start ART)** : គឺជាអ្នកជំងឺដែលកំពុងព្យាបាលជំងឺឱកាសនិយម ហើយស្ថិតក្នុងលក្ខ័ណ្ឌណាមួយដែលត្រូវចាប់ផ្តើមទទួល ART នៅក្នុងត្រីមាស ។ (ឧ. ប្រសិនបើចាប់ផ្តើម ART ប្រើសញ្ញា ✓ប្រសិនបើមិនចាប់ផ្តើម ART ទេ ទុកនៅទំនេរ)។

**ថ្ងៃ ខែ ឆ្នាំ** ៖ គឺជាកាលបរិច្ឆេទចុងក្រោយដែលអ្នកជំងឺត្រូវបានចាត់ទុកថា បាត់មុខ, ស្លាប់ និង ចាប់ផ្តើម ART (ឧ. អ្នកជំងឺបានលះបង់ការព្យាបាលនៅថ្ងៃទី ០១ខែវិច្ឆិកាឆ្នាំ២០១០)។

**៨- ខែទី១ (ធ្វើរហូតដល់ខែទី១២ដូចៗគ្នា)**

**ថ្ងៃខែឆ្នាំពិនិត្យ** ៖ គឺជាកាលបរិច្ឆេទប្រចាំខែនិមួយៗដែលអ្នកជំងឺម្នាក់ៗបានមកទទួលការពិនិត្យ និងព្យាបាល (ឧ. អ្នកជំងឺបានមកពិនិត្យនិងព្យាបាលនៅថ្ងៃទី ០១ខែវិច្ឆិកាឆ្នាំ២០១០)។

**មានផ្ទៃពោះ ៖** មានន័យថាបើអ្នកជំងឺជាស្ត្រី តើស្ត្រីនោះមានផ្ទៃពោះថ្មីដែរ រឺទេ (ឧ.ប្រសិនបើស្ត្រីនោះមានផ្ទៃពោះ ប្រើសញ្ញា ✓ បើគ្មានផ្ទៃពោះថ្មីទេទុកនៅទំនេរ) ការរាប់ថាស្ត្រីមានផ្ទៃពោះដោយគូសសញ្ញា ✓ គឺគូសតែម្តងគត់នៅពេលដែលគ្រូពេទ្យដឹងថាស្ត្រីនោះមានផ្ទៃពោះ ។

**ពិនិត្យសុខភាពរករោគសញ្ញាជំងឺរបេង:** មានន័យថាអ្នកជំងឺម្នាក់នោះនៅពេលដែលគាត់មកពិនិត្យសុខភាពលើកដំបូង (ថ្មី) រឺរាល់លើកដែលគាត់មកពិនិត្យហើយគាត់បានទទួលការពិនិត្យសុខភាពរករោគសញ្ញាជំងឺរបេង។ ប្រសិនបើរកឃើញថាគាត់មានរោគសញ្ញាណាមួយក្នុងចំណោមរោគសញ្ញាទាំងបីតាមរយៈការសាកសួររបស់លោកគ្រូពេទ្យ ត្រូវដាក់សញ្ញា **(+)** (ដែលមានន័យថាមាន) ប៉ុន្តែប្រសិនបើគាត់មិនមានរោគសញ្ញាណាមួយក្នុងចំណោមរោគស័ញ្ញាទាំងបីនោះទេ ត្រូវដាក់សញ្ញា **(-)** (ដែលមានន័យថាគ្មាន)។

**បានចាប់ផ្តើមព្យាបាលបង្ការដោយ INH (IPT started) :** មានន័យថាអ្នកជំងឺដែលបានមកពិនិត្យ និងព្យាបាលជារៀងរាល់ខែ គឺគាត់ស្ថិតនៅក្នុងលក្ខ័ណ្ឌណាមួយដែលត្រូវចាប់ផ្តើមព្យាបាលបង្ការដោយ **INH** ហើយគ្រូពេទ្យបានចាប់ផ្តើមផ្តល់ការព្យាបាលបង្ការដោយ **INH** (ឧ. ប្រសិនបើអ្នកជំងឺបានចាប់ផ្តើម ព្យាបាលបង្ការដោយ INH (IPT) ត្រូវប្រើសញ្ញា ✓ ប្រសិនបើមិនចាប់ផ្តើមព្យាបាលបង្ការដោយ IPT ទេទុកនៅទំនេរ)។

**បានចាប់ផ្តើមព្យាបាលបង្ការដោយ** Cotrimoxazole (CPT started) : មានន័យថាអ្នកជំងឺដែលបានមកពិនិត្យ និងព្យាបាលជារៀងរាល់ខែហើយគាត់ស្ថិតនៅក្នុងលក្ខ័ណ្ឌណាមួយដែលត្រូវចាប់ផ្តើមព្យាបាលបង្ការដោយ Cotrimoxazole ហើយគ្រូពេទ្យបានចាប់ផ្តើមផ្តល់ការព្យាបាលបង្ការដោយ CPT។ (ឧ. ប្រសិនបើអ្នកជំងឺបានចាប់ផ្តើមព្យាបាលបង្ការដោយ CPT ត្រូវប្រើសញ្ញា ✓ ប្រសិនបើមិនបានចាប់ផ្តើមព្យាបាលបង្ការដោយ CPT ទេ ទុកនៅទំនេរ)។

**រោគវិនិច្ឆ័យថាមានជំងឺរបេង** TB (BK+/-, EP) : មានន័យថាអ្នកជំងឺដែលបានមកពិនិត្យ និងព្យាបាលជារៀងរាល់ខែនៅពេលដែលគាត់មានរោគសញ្ញាណាមួយសង្ស័យថាមានជំងឺរបេង ត្រូវបានបញ្ជូនទៅធ្វើរោគវិនិច្ឆ័យច្បាស់លាស់នៅកម្មវិធីរបេងថា ហើយបានរកឃើញថាគាត់មានជំងឺរបេង ។ (ឧ. ប្រសិនបើអ្នកជំងឺនោះបានធ្វើរោគវិនិច្ឆ័យថាមានជំងឺរបេងទោះបីជាលទ្ធផលបញ្ជាក់ថា BK+/-, EP ត្រូវសរសេរ BK+, BK- រឺ EP ប្រសិនបើមិនមានជំងឺរបេងទេ ទុកនៅទំនេរ)។

**ចាប់ផ្តើមព្យាបាលជំងឺរបេង** TB TX : មានន័យថាអ្នកជំងឺដែលបានមកពិនិត្យ និងព្យាបាលជារៀងរាល់ខែ នៅពេលដែលគាត់បានធ្វើរោគវិនិច្ឆ័យច្បាស់លាស់ថាមានជំងឺរបេង ហើយបានចាប់ផ្តើមព្យាបាលជំងឺរបេង ។ (ឧ. ប្រសិនបើអ្នកជំងឺនោះបានចាប់ផ្តើមព្យាបាលជំងឺរបេងត្រូវប្រើសញ្ញា ✓ ប្រសិនបើមិនបានចាប់ផ្តើមព្យាបាលជំងឺរបេងទេ ទុកនៅទំនេរ)។

**កាបង្ការជាវិជ្ជមាន** (Positive Prevention) : មានន័យថាអ្នកជំងឺម្នាក់ៗដែលបានមកពិនិត្យនិងព្យាបាលជំងឺជារៀងរាល់ខែត្រូវបានអ្នកផ្តល់ប្រឹក្សារឺគ្រូពេទ្យ បានធ្វើការសាកសួរនិងផ្តល់នូវព័ត៌មានណាមួយក្នុងចំណោមចំនុចខាងក្រោម សូមប្រើសញ្ញា ✓ នៅក្នុងប្រអប់នីមួយៗ ៖

STI Prevention ៖ កាបង្ការជំងឺកាមរោគ

ART Adheareence ៖ ការផ្តល់ប្រឹក្សាអំពីការប្រើថ្នាំ ART

Birth Spacing ៖ ណែនាំអំពីការពន្យាកំណើត, ការរំលូតដោយសុវត្ថិភាព និងការមានផ្ទៃពោះដោយសុវត្ថិភាព

TB IC (TB Infection Control)៖ ណែនាំអំពីការបង្ការការចំលងមេរោគរបេង

Partner Status៖ ស្ថានភាពដៃគូ

Condom Used ៖ ការផ្តល់ប្រឹក្សាអំពីការប្រើប្រាស់ស្រោមអនាម័យ

សូមអរគុណ !